**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០៨៤ ប្រក

ថ្ងៃ អង្គារ ៤រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# ប្រកាស

## ស្ដីពី

## ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

# សម្រេច

**ប្រការ១ .—**

ប្រកាសនេះ មានគោលបំណងធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងលើកកម្ពស់សុវត្ថិភាពទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .—**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។

**ប្រការ៣ .—**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ .—**

លក្ខខណ្ឌនៃការវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ក្នុងដំណាក់កាលការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ត្រូវបានកំណត់ដូចខាងក្រោម៖

- ឧបសម្ព័ន្ធទី១ ៖ អំពីបរិវេណខាងមុខទីតាំង (៦០ ពិន្ទុ)
- ឧបសម្ព័ន្ធទី២ ៖ អំពីកន្លែងទទួលភ្ញៀវ (Lobby Area) (១០៥ ពិន្ទុ)
- ឧបសម្ព័ន្ធទី៣ ៖ អំពីបន្ទប់ទឹកសាធារណៈ (៥០ ពិន្ទុ)
- ឧបសម្ព័ន្ធទី៤ ៖ អំពីបន្ទប់ស្នាក់នៅ (៩៥ ពិន្ទុ)
- ឧបសម្ព័ន្ធទី៥ ៖ អំពីការគ្រប់គ្រង (២៤៥ ពិន្ទុ)
- ឧបសម្ព័ន្ធទី៦ ៖ តារាងត្រួតពិនិត្យសម្រាប់វាយតម្លៃ
- ឧបសម្ព័ន្ធទី៧ ៖ លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មសណ្ឋាគារ
- ឧបសម្ព័ន្ធទី៨ ៖ លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍។

**ប្រការ៥ .—**

អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដែលបានបំពេញតាមលក្ខខណ្ឌដូចបានកំណត់ក្នុងឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ ឧបសម្ព័ន្ធ៥ និងឧបសម្ព័ន្ធ៦ នៃប្រកាសនេះ នឹងទទួលបានលិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ ដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធ៧ និងឧបសម្ព័ន្ធ៨នៃប្រកាសនេះ។

**ប្រការ៦ .—**

វិធានសុវត្ថិភាពទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច និងជាលក្ខខណ្ឌបន្ថែមក្នុងការស្នើសុំថ្មីឬបន្តអាជ្ញាបណ្ណទេសចរណ៍។

គ្រប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់ដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍នេះ នឹងក្លាយជាកម្មវត្ថុនៃការព្យួរអាជ្ញាបណ្ណជាបន្ទាន់ស្របតាមមាត្រា៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ៧ .–**

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្តក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយអាចនឹងបន្តក្នុងដំណាក់កាលបន្តទៀតតាមការចាំបាច់។

អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវអនុវត្តតាមការណែនាំបន្ថែមរបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងករណីតម្រូវឱ្យរឹតបន្តឹងវិធានការរដ្ឋបាល។

**ប្រការ៨ .–**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ត្រូវចាត់ទុកជានិរាករណ៍នូវប្រកាសលេខ ០៨១ ប្រ.ក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។

**ប្រការ៩ .–**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**__កន្លែងទទួល៖__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  *"ដើម្បីជូនជ្រាប"*
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត

  *"ដើម្បីអនុវត្ត"*
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមសណ្ឋាគារកម្ពុជា

  *"ដើម្បីសហការ"*
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ១

## នៃប្រកាសលេខ..០៨៤.ប្រក..ចុះថ្ងៃទី..៣១..ខែ..សីហា..ឆ្នាំ២០២១

## ស្ដីពី

## "វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"

## "អំពីបរិវេណខាងមុខទីតាំង" (៦០ពិន្ទុ)

### ១.១. ការណែនាំអនុវត្តនៅច្រកចេញ-ចូល

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ១.១.១ | មានបុគ្គលិកប្រចាំការ ឬបំពាក់ម៉ាស៊ីនត្រួតពិនិត្យកម្ដៅដោយស្វ័យប្រវត្តិនិងមានបញ្ជូនសញ្ញានៅច្រកចេញចូល។ និងតម្រូវឱ្យជនគ្រប់រូបត្រូវវាស់កម្ដៅមុនចូល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ១.១.២ | មានបុគ្គលិកប្រចាំការ ឬបំពាក់ម៉ាស៊ីនបាញ់អាល់កុល/ថ្នាំសម្លាប់មេរោគដោយស្វ័យប្រវត្តិ(ស្របតាមបទដ្ឋាន)នៅច្រកចេញចូល។ និងតម្រូវឱ្យជនគ្រប់រូបត្រូវលាងដៃ ឬដើរឆ្លងកាត់ម៉ាស៊ីនសម្លាប់មេរោគមុនចូល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ១.១.៣ | មានបុគ្គលិកប្រចាំការ ឬស្លាកសញ្ញាសម្គាល់ទីតាំងត្រូវឈរតម្រង់ជួរចេញចូល និងត្រូវរក្សាគម្លាតសុវត្ថិភាព (១,៥ម៉ែត្រ)។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ១.១.៤ | មានបុគ្គលិកប្រចាំការ និងស្លាកសញ្ញាណែនាំនិងតម្រូវឱ្យជនគ្រប់រូបដែលចូលមកក្នុងទីតាំងអាជីវកម្មត្រូវចុះឈ្មោះក្នុងប្រព័ន្ធ QR CODE ទប់ស្កាត់កូវីដ-១៩ www.Stop COVID19.gov.kh របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| ១.១.៥ | មានបិទផ្សាយខ្លឹមសារជូនដំណឹងជាមុននៅច្រកចេញចូល អំពីកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាត និងប្រភេទទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើស។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន............ | ៣៥ |

### ១.២. ការណែនាំអនុវត្តចំពោះបុគ្គលិកនៅច្រកចេញ-ចូល

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ១.២.១ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្ដុះបណ្ដាល ឬទទួលបានការណែនាំអំពីចំនុចត្រូវត្រួតពិនិត្យមុននឹងអនុញ្ញាតឱ្យអ្នកណាម្នាក់ចូលក្នុងបរិវេណអាជីវកម្ម | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |

| | | | |
|---|---|---|---|
| ១.២.២ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធានការ “**៣ការពារ ៣កុំ**” | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ១.២.៣ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីលក្ខណៈសម្គាល់រោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន និងការយល់ដឹងអំពីវិធីសាស្ត្រអនុវត្តប្រសិនបើសង្កេតឃើញនរណាម្នាក់មានរោគសញ្ញាសង្ស័យ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |
| ១.២.៤ | បុគ្គលិកប្រចាំការមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ មានពាក់ម៉ាស់ និងពាក់ស្រោមដៃជាប់ជាប្រចាំ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន | ២៥ |

-ពិន្ទុសរុបទទួលបានសម្រាប់ការវាយតម្លៃនៅបរិវេណខាងមុខទីតាំង គឺ ....../៦០ ពិន្ទុ ក្នុងនោះ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលចាំបាច់ គឺ ....../៥០ ពិន្ទុ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលមិនចាំបាច់ គឺ ....../១០ ពិន្ទុ

តំណាងភាគីអាជីវកម្មឈ្មោះ..............................................

ហត្ថលេខា ................................

ឈ្មោះ ......................................

តួនាទី.........................................

លេខទូរស័ព្ទ..............................

ថ្ងៃទី.............ខែ.............ឆ្នាំ...........

មន្ត្រីត្រួតពិនិត្យ

ហត្ថលេខា និងឈ្មោះ

ឧបសម្ព័ន្ធ២

នៃប្រកាសលេខ...០៨៤ ទ.ប្រក...ចុះថ្ងៃទី...៣១...ខែ...សីហា...ឆ្នាំ២០២១

ស្ដីពី

"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"

## "អំពីកន្លែងទទួលភ្ញៀវ (Lobby Area)" (១០៥ពិន្ទុ)

### ២.១. ការណែនាំអនុវត្តនៅកន្លែងទទួលភ្ញៀវ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ២.១.១ | បានរៀបចំកន្លែងទទួលភ្ញៀវជាកន្លែងមានខ្យល់ចេញចូល មិនមែនជាបន្ទប់បិទជិត ឬមានបំពាក់ម៉ាស៊ីនសម្លាប់មេរោគក្នុងបរិយាកាស(ស្របតាមបទដ្ឋានត្រឹមត្រូវ)។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ២.១.២ | បានរៀបចំកន្លែងអង្គុយរង់ចាំ ដែលរក្សាគម្លាតសុវត្ថិភាព (១,៥ម៉ែត្រ) និងមានបិទសញ្ញាសម្គាល់ត្រឹមត្រូវ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ២.១.៣ | បានរៀបចំជាបញ្ជរចុះឈ្មោះអេឡិចត្រូនិច សម្រាប់អ្នកបានកក់ទុកជាមុន។ មានជម្រើស និងលើកទឹកចិត្តចំពោះភ្ញៀវដែលកក់ទុកជាមុន។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០ |
| ២.១.៤ | បានរៀបចំកន្លែងទទួលភ្ញៀវ ដោយរក្សានូវអនាម័យជាប់ជាប្រចាំ និងមិនបានបង្ករលក្ខណៈណាមួយដែលអាចឱ្យភ្ញៀវចាបកាន់វត្ថុដែលបន្តគ្នាដោយមិនបានសម្អាតជាមុននោះឡើយ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ២.១.៥ | រៀបចំកន្លែងទទួលភ្ញៀវ ដោយបំពាក់របាំងខណ្ឌចែករវាងបុគ្គលិកនិងភ្ញៀវ និងពីភ្ញៀវម្នាក់ទៅភ្ញៀវម្នាក់ទៀត | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០ |
| ២.១.៦ | មានប្រើប្រាស់ប្រព័ន្ធចុះឈ្មោះភ្ញៀវស្នាក់នៅតាមប្រព័ន្ធអនឡាញ និងរាយការណ៍ជាប់ជាប្រចាំទៅក្រសួងទេសចរណ៍ ឬមានបំពាក់កាមេរ៉ាសុវត្ថិភាពនៅកន្លែងទទួលភ្ញៀវ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០ |
| ២.១.៧ | មានបិទផ្សាយខ្លឹមសារជូនដំណឹងជាមុននៅកន្លែងទទួលភ្ញៀវ អំពីកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាត និងប្រភេទទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើស។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ២.១.៨ | មានបិទផ្សាយខ្លឹមសារ ឬចាក់វីដេអូផ្សព្វផ្សាយអំពីខ្លឹមសារវិធានការ "៣ការពារ ៣កុំ" | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន.......... | ៨០ |

២.២. ការណែនាំអនុវត្តចំពោះបុគ្គលិកនៅកន្លែងទទួលទានអាហារ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ២.២.១ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីចំនុចត្រូវត្រួតពិនិត្យមុននឹងអនុញ្ញាតឱ្យអ្នកណាម្នាក់ចូលក្នុងបរិវេណកន្លែងទទួលភ្ញៀវ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |
| ២.២.២ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធានការ "៣ការពារ ៣កុំ" | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ២.២.៣ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីលក្ខណៈសម្គាល់រោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន និងការយល់ដឹងអំពីវិធីសាស្ត្រអនុវត្តប្រសិនបើសង្កេតឃើញនរណាម្នាក់មានរោគសញ្ញាសង្ស័យ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |
| ២.២.៤ | បុគ្គលិកប្រចាំការមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ មានពាក់ម៉ាស់ និងពាក់ស្រោមដៃជាប់ជាប្រចាំ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន........... | ២៥ |

ថ្ងៃទី...........ខែ............ឆ្នាំ..........

មន្ត្រីត្រួតពិនិត្យ

ហត្ថលេខា និងឈ្មោះ

-ពិន្ទុសរុបទទួលបានសម្រាប់ការវាយតម្លៃនៅកន្លែងទទួលទានអាហារ គឺ ......./១០៥ ពិន្ទុ ក្នុងនោះ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលចាំបាច់ គឺ ......../៦៥ ពិន្ទុ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលមិនចាំបាច់ គឺ ......../៤០ ពិន្ទុ

តំណាងភាគីអាជីវកម្មឈ្មោះ...............................................

ហត្ថលេខា .........................................

ឈ្មោះ...............................................

តួនាទី...............................................

លេខទូរស័ព្ទ..........................................

# ឧបសម្ព័ន្ធ៣

## នៃប្រកាសលេខ..០៨៤ ប្រក...ចុះថ្ងៃទី..៣១...ខែ..សីហា...ឆ្នាំ២០២១

## ស្តីពី

## "វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"

## "អំពីបន្ទប់ទឹកសាធារណៈ" (៥០ពិន្ទុ)

### ៣.១. ការណែនាំអនុវត្តនៅបន្ទប់ទឹកសាធារណៈ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៣.១.១ | បានរៀបចំបន្ទប់ទឹកសាធារណៈជាកន្លែងមានខ្យល់ចេញចូល ឬមានបំពាក់ម៉ាស៊ីនសម្លាប់មេរោគក្នុងបរិយាកាស(ស្របតាមបទដ្ឋានត្រឹមត្រូវ) និងមានបញ្ជាក់ចំណុះផ្ទុកសម្រាប់ទីតាំងបន្ទប់ទឹកសាធារណៈនីមួយៗ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ៣.១.២ | មានបុគ្គលិកប្រចាំការ ឬស្លាកសញ្ញាសម្គាល់ទីតាំងត្រូវឈរតម្រង់ជួរចេញចូលបន្ទប់ទឹក និងត្រូវរក្សាគម្លាតសុវត្ថិភាព (១,៥ម៉ែត្រ) | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* |
| ៣.១.៣ | មានបិទផ្សាយខ្លឹមសារជូនដំណឹងជាមុននៅក្នុងបន្ទប់ទឹកសាធារណៈ អំពីកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាត និងប្រភេទទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើស | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥ |
| ៣.១.៤ | មានបិទផ្សាយខ្លឹមសារ អំពីរបៀបលាងដៃឱ្យបានត្រឹមត្រូវ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥ |
| | សរុប | ពិន្ទុធ្វើបាន........... | ២៥ |

### ៣.២. ការណែនាំអនុវត្តចំពោះបុគ្គលិកប្រចាំការនៅបន្ទប់ទឹកសាធារណៈ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៣.២.១ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីចំនុចត្រូវត្រួតពិនិត្យមុននឹងអនុញ្ញាតឱ្យអ្នកណាម្នាក់ចេញ-ចូលបន្ទប់ទឹក | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥ |
| ៣.២.២ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធានការ "៣ការពារ ៣កុំ" | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* |
| ៣.២.៣ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីលក្ខណៈសម្គាល់រោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន និងការយល់ដឹងអំពីវិធីសាស្រ្តអនុវត្តប្រសិនបើសង្កេតឃើញនរណាម្នាក់មានរោគសញ្ញាសង្ស័យ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥ |

| | | | |
|---|---|---|---|
| ៣.២.៤ | បុគ្គលិកប្រចាំការមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ មានពាក់ម៉ាស់ និងពាក់ស្រោមដៃជាប់ជាប្រចាំ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន........... | ២៥ |

-ពិន្ទុសរុបទទួលបានសម្រាប់ការវាយតម្លៃបន្ទប់ទឹកសាធារណៈ

គឺ ......../៥០ ពិន្ទុ ក្នុងនោះ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលចាំបាច់ គឺ ......../៣០ ពិន្ទុ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលមិនចាំបាច់ គឺ ......../២០ ពិន្ទុ

តំណាងភាគីអាជីវកម្មឈ្មោះ..............................................

ហត្ថលេខា ......................................

ឈ្មោះ..............................................

តួនាទី.............................................

លេខទូរស័ព្ទ......................................

ថ្ងៃទី........... ខែ............. ឆ្នាំ...........

មន្ត្រីត្រួតពិនិត្យ

ហត្ថលេខា និងឈ្មោះ

## ឧបសម្ព័ន្ធ៤

## នៃប្រកាសលេខ..០៨៤ ប្រក..ចុះថ្ងៃទី..៣១..ខែ..សីហា..ឆ្នាំ២០២១

## ស្តីពី

## "វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"

## "អំពីបន្ទប់ស្នាក់នៅ" (៩៥ពិន្ទុ)

### ៤.១. ការណែនាំអនុវត្តនៅបន្ទប់ស្នាក់នៅ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៤.១.១ | បានរៀបចំបន្ទប់ស្នាក់នៅត្រឹមត្រូវតាមបទដ្ឋាន មានបង្អួចអាចបើកឱ្យខ្យល់អាកាសចេញចូលបាន | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ៤.១.២ | បន្ទប់ស្នាក់នៅដាច់ដោយឡែក និងមានបន្ទប់ទឹកដោយឡែកនៅក្នុងបន្ទប់ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ៤.១.៣ | បន្ទប់ស្នាក់នៅមានបំពាក់ម៉ាស៊ីនសម្លាប់មេរោគក្នុងបរិយាកាស (ស្របតាមបទដ្ឋានត្រឹមត្រូវ) | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០ |
| ៤.១.៤ | បានរៀបចំបន្ទប់ស្នាក់នៅ ដោយរក្សានូវអនាម័យជាប់ជាប្រចាំ និងមិនបានបង្ករលក្ខណៈណាមួយដែលអាចឱ្យភ្ញៀវចាប់កាន់វត្ថុដដែលបន្តគ្នាដោយមិនបានសម្អាតជាមុននោះឡើយ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ៤.១.៥ | មានបិទផ្សាយប្រព័ន្ធស្ទង់មតិរបស់ភ្ញៀវនៅក្នុងបន្ទប់ស្នាក់នៅ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០ |
| ៤.១.៦ | មានបិទផ្សាយខ្លឹមសារជូនដំណឹងជាមុននៅក្នុងបន្ទប់ស្នាក់នៅ អំពីកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាត និងប្រភេទទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើស | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| ៤.១.៧ | មានបិទផ្សាយខ្លឹមសារ ឬចាក់វីដេអូផ្សព្វផ្សាយអំពីខ្លឹមសារវិធានការ "៣ការពារ ៣កុំ" | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន........... | ៧០ |

### ៤.២. ការណែនាំអនុវត្តចំពោះបុគ្គលិកសម្អាតនៅក្នុងបន្ទប់ស្នាក់នៅ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|

| | | | |
|---|---|---|---|
| ៤.២.១ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីចំនុចត្រូវត្រួតពិនិត្យមុននឹងអនុញ្ញាតឱ្យអ្នកណាម្នាក់ចូលក្នុងបរិវេណបន្ទប់ស្នាក់នៅ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |
| ៤.២.២ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធានការ "**៣ការពារ ៣កុំ**" | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ៤.២.៣ | បុគ្គលិកប្រចាំការ ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីលក្ខណៈសម្គាល់រោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន និងការយល់ដឹងអំពីវិធីសាស្ត្រអនុវត្តប្រសិនបើសង្កេតឃើញនរណាម្នាក់មានរោគសញ្ញាសង្ស័យ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |
| ៤.២.៤ | បុគ្គលិកប្រចាំការមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ មានពាក់ម៉ាស់ និងពាក់ស្រោមដៃជាប់ជាប្រចាំ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន........... | ២៥ |

-ពិន្ទុសរុបទទួលបានសម្រាប់ការវាយតម្លៃនៅកន្លែងទទួលទានអាហារ គឺ ......./៩៥ ពិន្ទុ ក្នុងនោះ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលចាំបាច់ គឺ ......../៦៥ ពិន្ទុ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលមិនចាំបាច់ គឺ ......../៣០ ពិន្ទុ

តំណាងភាគីអាជីវកម្មឈ្មោះ...............................................

ហត្ថលេខា .........................................

ឈ្មោះ...................................................

តួនាទី...................................................

លេខទូរស័ព្ទ.........................................

ថ្ងៃទី...........ខែ............ឆ្នាំ..........

**មន្ត្រីត្រួតពិនិត្យ**

ហត្ថលេខា និងឈ្មោះ

## ឧបសម្ព័ន្ធ៥

## នៃប្រកាសលេខ..០៨៤ ប្រក..ចុះថ្ងៃទី..៣១..ខែ..សីហា..ឆ្នាំ២០..២១

## ស្តីពី

## "វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍"

## "អំពីការគ្រប់គ្រង" (២៤៥ពិន្ទុ)

### ៥.១. ការប្រើប្រាស់បច្ចេកវិទ្យា

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៥.១.១ | មានឧបករណ៍វាស់កម្ដៅស្វ័យប្រវត្តិ ត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ៥ |
| ៥.១.២ | មានឧបករណ៍បាញ់អាល់កុល ឬទឹកថ្នាំសម្លាប់មេរោគ(សម្រាប់លាងដៃ ឬសព្វខ្លួនប្រាណ) ត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ៥ |
| ៥.១.៣ | មានឧបករណ៍សម្លាប់មេរោគក្នុងបរិយាកាស ត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ១០ |
| ៥.១.៤ | ប្រើប្រាស់ទ្វារបិទបើកដោយស្វ័យប្រវត្តិ ត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ១០ |
| ៥.១.៥ | ប្រើប្រាស់ប្រព័ន្ធបិទបើកភ្លើងបំភ្លឺដោយស្វ័យប្រវត្តិ ត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ១០ |
| ៥.១.៦ | ប្រើប្រាស់ប្រព័ន្ធបិទបើកទឹកប្រើប្រាស់ដោយស្វ័យប្រវត្តិ ត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ១០ |
| ៥.១.៧ | បំពាក់កាមេរ៉ាសុវត្ថិភាពត្រឹមត្រូវនិងគ្រប់គ្រាន់ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ១០ |
| ៥.១.៨ | បំពាក់បច្ចេកវិទ្យាឬវិធីសាស្ត្រអនុវត្តជំនួសឱ្យការទំនាក់ទំនងដោយប្រើសំលេងខ្លាំងៗ | □ គ្រប់គ្រាន់<br>□ មិនគ្រប់គ្រាន់ | ១០ |
| | សរុប | ពិន្ទុធ្វើបាន........... | ៧០ |

### ៥.២. ការណែនាំអនុវត្តចំពោះបុគ្គលិកទូទៅ

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|



ក្រសួងទេសចរណ៍ ... រដ្ឋមន្ត្រី

| | | | |
|---|---|---|---|
| ៥.២.១ | បុគ្គលិកសម្អាតធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីចំនុចត្រូវអនុវត្តរាល់ពេលសម្អាតម្តងៗ និងមានវេណសម្អាតត្រឹមត្រូវ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| ៥.២.២ | បុគ្គលិកសម្អាតធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធានការ "៣ការពារ ៣កុំ" | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ៥.២.៣ | បុគ្គលិកសម្អាតធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីលក្ខណៈសម្គាល់រោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន និងការយល់ដឹងអំពីវិធីសាស្ត្រអនុវត្តប្រសិនបើសង្កេតឃើញនរណាម្នាក់មានរោគសញ្ញាសង្ស័យ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥ |
| ៥.២.៤ | បុគ្គលិកសម្អាតមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ មានពាក់ម៉ាស់ និងពាក់ស្រោមដៃជាប់ជាប្រចាំ និងលាងដៃឲ្យបានញឹកញ៉ាប់រៀងរាល់ ២០នាទីម្តង | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន........... | ៣០ |

## ៥.៣. ការណែនាំអនុវត្តចំពោះបុគ្គលិកផ្តល់សេវាកម្មដឹកជញ្ជូន

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៥.៣.១ | បុគ្គលិកផ្នែកដឹកជញ្ជូនធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីចំណុចត្រូវអនុវត្តរាល់ពេលប្រតិបត្តិការ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| ៥.៣.២ | បុគ្គលិកផ្នែកដឹកជញ្ជូនធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធាន (៣ការពារ ៣កុំ) | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* |
| ៥.៣.៣ | បុគ្គលិកផ្នែកដឹកជញ្ជូនមានឯកសណ្ឋានត្រឹមត្រូវ សមរម្យមានពាក់ម៉ាស់ និងលាងដៃឱ្យបានញឹកញាប់រៀងរាល់ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| ៥.៣.៤ | លាងសម្អាតសម្ភារៈ និងមធ្យោបាយដឹកជញ្ជូនឱ្យបានញឹកញាប់ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| | សរុប | ពិន្ទុធ្វើបាន........... | ៣៥ |

## ៥.៤. ការជម្រុញ និងលើកទឹកចិត្តការចូលរួមរបស់បុគ្គលិក

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៥.៤.១ | បង្កលក្ខណៈ ងាយស្រួល និងលើកទឹកចិត្តឱ្យបុគ្គលិកទាំងអស់ត្រូវចាក់វ៉ាក់សាំង | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* |
| ៥.៤.២ | បញ្ចូលឈ្មោះ និងទិន្នន័យបុគ្គលិកបានចាក់វ៉ាក់សាំងទៅក្នុងប្រព័ន្ធចុះឈ្មោះ "ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងវិស័យទេសចរណ៍" | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ២០* |

| | | | |
|---|---|---|---|
| ៥.៤.៣ | មានគោលនយោបាយគាំទ្រ ឬអនុគ្រោះចំពោះបុគ្គលិកជាប់ចត្តាឡីស័ក ឬត្រូវសម្រាកព្យាបាលជំងឺកូវីដ-១៩ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០ |
| | សរុប | ពិន្ទុធ្វើបាន........... | ៤០ |

**៥.៥. ការជម្រុញ និងលើកទឹកចិត្តការចូលរួមរបស់ភ្ញៀវ**

| ល.រ | សកម្មភាពតម្រូវ | ការត្រួតពិនិត្យ | ពិន្ទុ |
|---|---|---|---|
| ៥.៥.១ | មានកម្មវិធីលើកទឹកចិត្តចំពោះភ្ញៀវដែលបានបង្ហាញកាតចាក់វ៉ាក់សាំង២ដូសរួចរាល់ និងអត្តសញ្ញាណបណ្ណ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ២០ |
| ៥.៥.២ | មានកម្មវិធីលើកទឹកចិត្តចំពោះភ្ញៀវដែលមិនពិសារគ្រឿងស្រវឹង | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ២០ |
| | សរុប | ពិន្ទុធ្វើបាន........... | ៤០ |

-ពិន្ទុសរុបទទួលបានសម្រាប់ការវាយតម្លៃការគ្រប់គ្រង
គឺ ......../២១៥ ពិន្ទុ ក្នុងនោះ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលចាំបាច់ គឺ ....../៨០ ពិន្ទុ

+ពិន្ទុសម្រាប់ចំនុចត្រួតពិនិត្យដែលមិនចាំបាច់ គឺ ......./១៣៥ ពិន្ទុ

តំណាងភាគីអាជីវកម្មឈ្មោះ.............................................

ហត្ថលេខា .............................................

ឈ្មោះ................................................

តួនាទី................................................

លេខទូរស័ព្ទ.........................................

ថ្ងៃទី...........ខែ............ឆ្នាំ..........

**មន្ត្រីត្រួតពិនិត្យ**

ហត្ថលេខា និងឈ្មោះ

# ឧបសម្ព័ន្ធ៦

## នៃប្រកាសលេខ...០៤៨/ប្រក...ចុះថ្ងៃទី...៣១...ខែ...សីហា...ឆ្នាំ២០២១

## ស្ដីពី

## “វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍”

**<u>តារាងត្រួតពិនិត្យសម្រាប់វាយតម្លៃ</u>**

| ល.រ | ចំណុចត្រួតពិនិត្យ | ការវាយតម្លៃ | | | |
|---|---|---|---|---|---|
| | | ការត្រួតពិនិត្យសរុប | | ការត្រួតពិនិត្យចាំបាច់ | |
| | | ចំណុច | ពិន្ទុ | ចំណុច | ពិន្ទុ |
| ១ | **អំពីបរិវេណខាងមុខទីតាំង** | ៩ | ៦០ | ៧ | ៥០ |
| | ១.១. ការណែនាំអនុវត្តនៅច្រកចេញ-ចូល | ៥ | ៣៥ | ៥ | ៣៥ |
| | ១.២. ការណែនាំអនុវត្តចំពោះបុគ្គលិកនៅច្រកចេញ-ចូល | ៤ | ២៥ | ២ | ១៥ |
| ២ | **អំពីកន្លែងទទួលភ្ញៀវ(Lobby Area)** | ១២ | ១០៥ | ៧ | ៦៥ |
| | ២.១. ការណែនាំអនុវត្តនៅកន្លែងទទួលភ្ញៀវ | ៨ | ៨០ | ៥ | ៥០ |
| | ២.២. ការណែនាំអនុវត្តចំពោះបុគ្គលិកនៅកន្លែងទទួលភ្ញៀវ | ៤ | ២៥ | ២ | ១៥ |
| ៣ | **អំពីបន្ទប់ទឹកសាធារណៈ** | ៨ | ៥០ | ៤ | ៣០ |
| | ៣.១. ការណែនាំអនុវត្តនៅបន្ទប់ទឹកសាធារណៈ | ៤ | ២៥ | ២ | ១៥ |
| | ៣.២. ការណែនាំអនុវត្តចំពោះបុគ្គលិកប្រចាំការនៅបន្ទប់ទឹកសាធារណៈ | ៤ | ២៥ | ២ | ១៥ |
| ៤ | **អំពីបន្ទប់ស្នាក់នៅ** | ១១ | ៩៥ | ៧ | ៦៥ |
| | ៤.១. ការណែនាំអនុវត្តនៅបន្ទប់ស្នាក់នៅ | ៧ | ៧០ | ៥ | ៥០ |
| | ៤.២. ការណែនាំអនុវត្តចំពោះបុគ្គលិកសម្អាតនៅក្នុងបន្ទប់ស្នាក់នៅ | ៤ | ២៥ | ២ | ១៥ |
| ៥ | **អំពីការគ្រប់គ្រង** | ២១ | ២១៥ | ៩ | ៩០ |
| | ៥.១. ការប្រើប្រាស់បច្ចេកវិទ្យា | ៨ | ៧០ | ០ | ០ |
| | ៥.២. ការណែនាំអនុវត្តចំពោះបុគ្គលិកទូទៅ | ៤ | ៣០ | ៣ | ២៥ |
| | ៥.៣. ការណែនាំអនុវត្តចំពោះបុគ្គលិកផ្ដល់សេវាកម្មដឹកជញ្ជូន | ៤ | ៣៥ | ៤ | ៣៥ |

| | | | | | |
|---|---|---|---|---|---|
| | ៥.៤. ការជម្រុញ និងលើកទឹកចិត្តការចូលរួមរបស់បុគ្គលិក | ៣ | ៤០ | ២ | ៣០ |
| | ៥.៥. ការជម្រុញ និងលើកទឹកចិត្តការចូលរួមរបស់ភ្ញៀវ | ២ | ៤០ | ០ | ០ |
| | <u>សរុបរួម</u> | ៦១ | ៥២៥ | ៣៤ | ៣០០ |

"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍" មាន **៦១ចំណុចត្រូវវាយតម្លៃស្មើនឹង ៥២៥ពិន្ទុ។**

អាជីវកម្មដែលចាត់ទុកជាអនុវត្តត្រឹមត្រូវតាម **"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍"** និងទទួលបានលិខិតបញ្ជាក់ទទួលស្គាល់ជាអាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍បានអនុវត្តត្រឹមត្រូវតាម **"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍"**លុះត្រាតែ៖

- អាជីវកម្មទទួលបានពិន្ទុចាប់ពី ៨០% ឡើងទៅនៃពិន្ទុសរុប
- និងអាជីវកម្មបំពេញបានគ្រប់ចំណុចតម្រូវចាំបាច់ទាំង ៣៤ចំណុច។

លិខិតបញ្ជាក់នេះមានសុពលភាពរយៈពេលអតិបរមា ០១ឆ្នាំ។ លិខិតបញ្ជាក់នេះនឹងចាប់រាប់សុពលភាពចាប់ពីកាលបរិច្ឆេទសម្រេចផ្តល់លិខិតបញ្ជាក់ជូន រហូតដល់ការបញ្ចប់សុពលភាពនៅកាលបរិច្ឆេទដូចនឹងកាលបរិច្ឆេទបញ្ចប់សុពលភាពអាជ្ញាបណ្ណទេសចរណ៍ក្នុងឆ្នាំអនុវត្តតែមួយនោះ។

អាជីវកម្មដែលធ្លាប់ទទួលបានលិខិតបញ្ជាក់រួចហើយ នោះការបន្តស្នើសុំវាយតម្លៃ ដើម្បីទទួលបានលិខិតបញ្ជាក់ឆ្នាំអនុវត្តបន្ត គឺចាប់រាប់នៅពេលគាត់ស្នើសុំអាជ្ញាបណ្ណទេសចរណ៍។

ក្រសួងទេសចរណ៍

# ឧបសម្ព័ន្ធ៧

## នៃប្រកាសលេខ......០៨៤ ប្រក......ចុះថ្ងៃទី.....៣១.....ខែ.....សីហា.....ឆ្នាំ២០.....២១

## ស្ដីពី

## “វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍”

### លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មសណ្ឋាគារ
### ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍

Logo
រដ្ឋបាលរាជធានី-ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី-ខេត្ត
លេខ:..................

**លិខិតបញ្ជាក់**

ជូន

អាជីវកម្មឈ្មោះ....................................................................................................

អក្សរឡាតាំង........................................................................................................

ដែលបានអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មសណ្ឋាគារ

សុពលភាពគិតចាប់ពីថ្ងៃទី.......................................ដល់ថ្ងៃទី.......................................

ទទួលបានពិន្ទុ.......................

ថ្ងៃ..................ខែ..................ឆ្នាំ..................ស័ក ព.ស.២៥.........

ថ្ងៃទី..................ខែ..................ឆ្នាំ..................

អភិបាលរាជធានី-ខេត្ត

ប្រធានមន្ទីរទេសចរណ៍

QR-Code

........................

........................

*សម្គាល់: ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍បន្ត នឹងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់នេះផងដែរ។

- ទំហំ A4 (ប្រវែងទទឹង ២១សម នឹងប្រវែងបណ្ដោយ ២៩,៦សម)

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងទេសចរណ៍